Go Digital ASEAN

The Asia Foundation

# កម្មវិធីបណ្ដុះបណ្ដាល

# ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការប្រកបអាជីវកម្ម

Our partner:

With support from: Google.org

# ស្វាគមន៍មកកាន់



# វគ្គបណ្តុះបណ្តាល ជំនាញឌីជីថល

# ខ្លឹមសារមេរៀន

## ប្រធានបទទាំង 5 សម្រាប់ការបង្រៀន

1. ការបង្កើតទំព័រ Facebook (Facebook page creation)
2. ការបង្កើត មាតិកា/ខ្លឹមសាសម្រាប់ ផ្សព្វផ្សាយពីអាជីវកម្ម (Content creation for business)
3. ការគ្រប់គ្រងទំព័រ Facebook (Facebook page management)
4. សុវត្ថិភាពលើប្រព័ន្ធអ៊ីនធឺណែត (Online safety)
5. ការកំណត់ផែនទីអាជីវកម្មនៅលើ Google Map ( Setup business location on Google Map)

# កម្មវិធីដែលត្រូវទាញយក

**Facebook Business Suite**

**Inshot** - Photo editor and video maker

# 01. ការបង្កើតទំព័រហ្វេសប៊ុក

## តើទំព័រហ្វេសប៊ុកជាអ្វី?

ទំព័រហ្វេសប៊ុក គឺជាទំព័រសាធារណៈដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់អាជីវកម្ម និងការប្រើប្រាស់សាធារណៈដទៃទៀត។ មិនដូចគណនីផ្ទាល់ខ្លួនទេ ទំព័រអាចទទួលបានអ្នកគាំទ្រច្រើនជាងគណនីផ្ទាល់ខ្លួន និងមានមុខងារដើម្បីជួយទៅលើអាជីវកម្មបានច្រើន។

## ហេតុអ្វីទំព័រហ្វេសប៊ុកសំខាន់?

- អាចទទួលបានអតិថិជនច្រើនជាង ៥០០០ នាក់ (Like)
- អាចពង្រីកការផ្សព្វផ្សាយតាមការប្រើប្រាស់ថវិការ (Boosting)
- អាចវិភាគទិន្នន័យនៃការផ្សព្វផ្សាយរបស់អ្នក (Facebook Insight)
- អាចដាក់កាលវិភាគក្នុងសម្រាប់ការផ្សព្វផ្សាយនីមួយៗបាន (Schedule Post)
- អាចបែងចែកតួនាទីនៃការគ្រប់គ្រងបាន (Page Roles)

# របៀបបង្កើតទំព័រហ្វេសប៊ុក




ចូលទៅកាន់ Facebook របស់អ្នក រួចចុចសញ្ញា ទង់ជាតិដូចមានក្នុងរូប




ចុចពាក្យ បង្កើត ដែលមានសញ្ញាបូក




ចុចពាក្យ ចាប់ផ្តើម




ទី1 ត្រូវដាក់ឈ្មោះហាងរបស់អ្នក ជាខ្មែរ ឬអង់គ្លេស ឬលាយគ្នាក៏បាន។

ទី២ ហើយចុចពាក្យ បន្ទាប់













ទី1 ជ្រើសប្រភេទហាង របស់អ្នក។
ឧទា: លក់សំលៀកបំពាក់
ទី2 ហើយចុចពាក្យ បន្ទាប់

ទី1 ការដាក់គេហទំព័រ
ទី2 បើមិនមាន ចុចធីកក្នុងប្រអប់ **ខ្ញុំមិនមានគេហទំព័រ** ហើយចុច ពាក្យ បន្ទាប់

ទី1 ជ្រើសរូបភាព ក្នុងក្រប (Cover) និង (Profile)
ទី2 ហើយចុចពាក្យ ធ្វើរួច

ឥឡូវអ្នកបានបង្កើត ទំព័រFacebookរួចហើយ។

# ដើម្បីចូលទៅកាន់ទំព័រដែលបង្កើតហើយ




ចូលទៅកាន់ Facebook របស់អ្នក រួចចុចសញ្ញាទង់ជាតិដូចមានក្នុងរូប




ចុចលើ ទំព័រ Facebook ដែលអ្នកទើបតែបង្កើត




ចុចលើ Page សញ្ញាទង់ជាតិដូចមានក្នុងរូប




នេះគឺជា ទំព័រ Facebook របស់អ្នក

# 02. ការបង្កើតមាតិកាឌីជីថល

## ធាតុសំខាន់ៗនៃការថតរូបល្អជាមួយទូរស័ព្ទ

### ពន្លឺ




### ពណ៌




### ការចាប់ប្លង់



# ប្លង់សំខាន់ៗ

## ច្បាប់ចែកបី
## Rule of Third



បើកមុខងារដែលមានបន្ទាត់ដូចក្នុងរូប ក្នុងទូរសព្ទ័របស់អ្នក។ បន្ទាប់មកដាក់ផលិតផលដែលអ្នកចង់ថតអោយនៅចំ ចំនុចកែងដូចបានបង្ហាញក្នុងរូបខាងលើ។

## ថតពីលើ



រៀបផលិតផលដែលអ្នកចង់ថតនៅលើផ្ទៃរាប់ រួចបន្ថែមផ្កា ឬស្លឹកឈើដើម្បីបន្ថែមសោភណភាព បន្ទាប់មកយកទូរសព្ទ័អ្នកថតអោយចំពីលើនោះ។

## ចំកណ្ដាលព្រាលក្រោយ




ដាក់ផលិតផលដែលអ្នកចង់ថតអោយនៅចំកណ្ដាល នឹងរៀបចំផ្កាឬស្លឹកឈើនៅពីក្រោយ បន្ទាប់មកដាក់ទូរសព្ទ័របស់អ្នកអោយនៅជិតផលិតផល ដើម្បីបានព្រាលក្រោយ។

# កម្មវិធីកែរូបភាពលើទូរស័ព្ទ

Inshot – video edit & photo

Snapseed

PIXLR

Adobe Photoshop Express

# ការបង្កើតចំណងជើងហ្វេសប៊ុក

01

## ការប្រើប្រាស់លេខ

អ្នកអាចប្រើប្រាស់លេខក្នុងចំណងជើងផុសរបស់អ្នកដូចជា ប្រជាជន៨០%ចូលចិត្តផលិតផលនេះ ផលិតផលនេះបានជួយមនុស្សជាង១០ម៉ឺននាក់

02

## ការប្រើប្រាស់សំណួរ

អ្នកអាចប្រើប្រាស់សំណួរក្នុងចំណងជើងផុសរបស់អ្នកដូចជា តើអ្នកត្រៀមខ្លួនហើយឬនៅ? តើអ្នកនៅចាំអីទៀត? តើមានអ្វីនឹងកើតមាន?

03

## ការប្រើប្រាស់អារម្មណ៍

អ្នកអាចប្រើប្រាស់អារម្មណ៍ក្នុងចំណងជើងផុសរបស់អ្នកដូចជា ផលិតផលដែលជួយអោយអ្នកមានអារម្មណ៍ស្រស់ស្រាយ

04

## ប្រម៉ូសិន

អ្នកអាចប្រើប្រាស់ប្រម៉ូសិនក្នុងចំណងជើងផុសរបស់អ្នកដូចជា ទិញ១ថែម១ បញ្ចុះតម្លៃប្រចាំខែ ការដឹកជញ្ជូនឥតគិតថ្លៃ

# 03. ការគ្រប់គ្រង់ផេក Facebook

## របៀបបង្កើតផុស(Post) ក្នុង App (Facebook Business Suite) គ្រប់គ្រងផេក




ចូលទៅកាន់ Facebook Business Suite, ចុចពាក្យ Post ដែលមានសញ្ញា




ផុស រូបថត ឬវីដេអូ

ផុស ដែលដាក់ជាមួយទីតាំងរបស់អ្នក

ផុស អារម្មណ៍ និងសកម្មភាព

ផុស បន្តផ្ទាល់ (Live)

ផុស ដោយមានប៊ូតុងឆាត (Chat)

ទី1 សរសេរចំនងជើងដែលអ្នកចង់បាន។

ទី2 ជ្រើសរើសប្រភេទមុខងារដែរអ្នកចង់ផុស




ចុចពាក្យ Next បន្ទាប់ពីជ្រើសរើសមុនងារដែលអ្នកចង់ផុស

ចុចកន្លែងរង្វង់ក្រហម ដើម្បីប្រភេទនៃការផុសរបស់អ្នក

ទី1 Post now គឺផុសឥឡូវ

ទី2 Schedule កំនត់កាលវិភាគផុស

ទី3 Save Draft ព្រាងទុក

បើសិនអ្នកចង់ដាក់កាលវិភាគ អ្នកត្រូវកំនត់វា ដោយ ទី1 ចុចដើម្បីជ្រើសថ្ងៃ ខែ ទី2 ចុចដើម្បីកំនត់ម៉ោងផុស ហើយចុច Set Date

ចុងក្រោយអ្នកត្រូវចុចពាក្យចំនុចរង្វង់ក្រហម ដែលមានពាក្យ PUBLISH ឬ Schedule

# ស្វែងរកកន្លែងដែលដាក់កាលវិភាគផុស










ចូលទៅកាន់ Facebook Business Suite, ចុចពាក្យរូបដែលមានរង្វង់ក្រហម

ទី1 ចុចពាក្យ Published
ទី2 ចុចពាក្យ Scheduled

# របៀបដាក់តួនាទីក្នុងផេក (Page Role)










ចូលទៅកាន់ Facebook Business Suite, ចុចពាក្យរូបដែលមានរង្វង់ក្រហម

ចុចពាក្យ Setting

ចុចពាក្យ Edit Page Roles













* ចុច Add Person to Page ដើម្បីដាក់អ្នកគ្រប់គ្រងបន្ថែម
** ចុចរូបខ្មៅដៃដើម្បីកែតួនាទីអ្នកដែលមានស្រាប់

បំពេញលេខសម្ងាត់ Facebook របស់អ្នក ដើម្បីទៅបន្ត

ចុចរង្វង់ក្រហមដើម្បីដាក់តួនាទី, គេត្រូវតែជា Friend ក្នុង Facebook របស់អ្នក, និង Like ផេករបស់អ្នករួច

ចុចលើមុខងារណាមួយ រួចចុច Add.
ចំណាំ៖ គេត្រូវ Accept ក្នុង Facebook របស់គេដែរ

# ការមើលទិន្នន័យ




## Reach

គឺជាទិន្នន័យអំពីចំនួន
មនុស្សដែលបានឃើញការ
ផុសរបស់អ្នក

## Like

គឺជាទិន្នន័យអំពីចំនួនមនុស្ស
ដែលបានចូលចិត្ត ឬបានបញ្ចេញ
អារម្មណ៍ជាមួយផុសរបស់អ្នក

## Comment

គឺជាទិន្នន័យអំពីចំនួនមនុស្ស
ដែលបានបញ្ចេញមតិយោបល់
លើការផុសរបស់អ្នក

## Share

គឺជាទិន្នន័យអំពីចំនួននៃ
ការចែករំលែកលើផុស
របស់អ្នក

# 04. សុវត្ថិភាពលើអ៊ីនធឺណិត

## អ្វីជាសុវត្ថិភាពលើអ៊ីនធឺណិត

សុវត្ថិភាពអ៊ិនធឺណិតត្រូវបានកំណត់ជាដំណើរការបង្កើតច្បាប់និងសកម្មភាពដើម្បីការពារប្រឆាំងនឹងការវាយប្រហារតាមអ៊ីនធឺណិត។ ឧទាហរណ៍នៃសុវត្ថិភាពអ៊ីនធ័រណេតគឺជាប្រព័ន្ធអ៊ីនធរណេតដែលរាំងលេខកាតឥណទានពីការលួចនៅលើគេហទំព័រទិញទំនិ

## ហេតុអ្វីបានជាវាសំខាន់?




- លេខសម្ងាត់ផ្តល់នូវការចូលប្រើប្រាស់គណនីសំខាន់ៗមួយចំនួនដូចជាអ៊ីមែលគណនីធនាគារ គេហទំព័រ បណ្តាញសង្គម។ ល។
- លេខសម្ងាត់ក៏ផ្តល់នូវការចូលប្រើឧបករណ៍មួយចំនួនផ្សេងទៀតដូចជាការចូលប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទ និងឯកសារទៀត។
- គណនី ឬឧបករណ៍ទាំងនេះច្រើនតែផ្ទុកព័ត៌មានផ្ទាល់ខ្លួនរបស់យើង

# របៀបបង្កើតពាក្យសម្ងាត់អោយរឹងមាំ




- ដាក់អោយកាន់តែវែង កាន់តែល្អ
  (យ៉ាងយោចណាស់៨តួ)
- ដាក់វាអោយស្មុគស្មាញ
  (ត្រូវមានលេខ អក្សរធំ អក្សរតូច សញ្ញាពិសេស)
- មិនត្រូវប្រើពាក្យដែលមានន័យក្នុងវចនានុក្រម
- មិនត្រូវប្រើព័ត៌មានដែលទាក់ទងនឹងអ្នក
  (ឈ្មោះ ថ្ងៃ ខែ ឆ្នាំ កំណើត...)
- មិនត្រូវប្រើពាក្យសម្ងាត់រួម

# វិធីសាស្ត្រក្នុងការចាក់សោរពីរជាន់




ចូលទៅកាន់ Facebook របស់អ្នក រួចចុចសញ្ញាគ្រែ 3 ដូចមានក្នុងរូប




បន្ទាប់មកចុចពាក្យ ការកំណត់និងឯកជនភាព




បន្ទាប់មកចុចពាក្យ ការកំណត់




បន្ទាប់មកចុចពាក្យ សុវត្ថិភាព និងការចុះឈ្មោះ

# វិធីសាស្ត្រក្នុងការចាក់សោរពីរជាន់













បន្ទាប់មកចុចពាក្យ ការផ្ទៀងផ្ទាតពីរកត្តា

ទី1 ចុចពាក្យ សារជាអក្សរ (SMS)
ទី2 ចុចពាក្យ បន្ត

ទី1 ជ្រើសរើសលេខទូរស័ព្ទ
ទី2 ចុចពាក្យ បន្ត

ទី1 យកលេខកូដដែលទទួលបានពី សារជាអក្សរ (SMS) ដាក់ចូល

# 05. ផែនទី Google

## តើអ្វីជាផែនទី Google Map?

Google Maps គឺជាសេវាកម្មបង្កើតផែនទីបណ្ដាញបង្កើតដោយហ្គូហ្គោល។ វាផ្ដល់នូវរូបភាពផ្កាយរណបការថតរូបពីលើអាកាស ផែនទីតាមចិញ្ចើមផ្លូវ រូប៣៦០° ទិដ្ឋភាពបែបផែនអន្តរកម្មនៃផ្លូវស្ថានភាពចរាចរណ៍ជាក់ស្ដែងនិងការធ្វើផែនការសម្រាប់ការធ្វើដំណើរដោយ ថ្មើរជើង រថយន្ត កង់ និងអាកាស ឬការដឹកជញ្ជូនសាធារណៈ។

## ហេតុអ្វីបានជាវាសំខាន់?

ផែនទី Google គ្រប់គ្រងស្ទើរតែពីរភាគបីនៃការស្វែងរកតាមអ៊ីនធឺណិត - ដែលមានចរាចរណ៍ច្រើន។ នេះធ្វើឱ្យ Google ផែនទីក្លាយជាឧបករណ៍សំខាន់បំផុតសម្រាប់ ការស្វែងរកតាមអ៊ីនធឺណិត។ អ្នកទស្សនារាប់លាននាក់ប្រើវាដើម្បីស្វែងរកទិសដៅទៅកាន់អាជីវកម្មក្នុងស្រុកការទាក់ទាញ និងអាសយដ្ឋានផ្ទាល់ខ្លួន។

# ការដៅផែនទីអាជីវកម្មនៅលើផែនទី Google




ដំបូងចូលទៅកាន់គេហទំព័រ Google.com/business បន្ទាប់មក ចុចពាក្យ Manage now




ចុចពាក្យ Add your business to Google




ទី១ ដាក់ឈ្មោះហាងរបស់អ្នក ជាខ្មែរ ឬអង់គ្លេស ឬលាយគ្នាក៏បាន។
ទី២ ហើយចុចពាក្យ Next




ទី1 ជ្រើសប្រភេទហាងរបស់អ្នក។
ឧទា: លក់សំលៀកបំពាក់
ទី2 ហើយចុចពាក្យ Next













ទី1 ជ្រើសរើសពាក្យ Yes
ទី2 ហើយចុចពាក្យ Next

ទី1 ដាក់អាសយដ្ឋានរបស់អ្នក
ទី2 ហើយចុចពាក្យ Next

ទី1 ចុចពាក្យ None of these
ទី2 ហើយចុចពាក្យ Next

ទី1 ជ្រើសរើសយកទីតាំងនៅលើផែនទី
ទី2 ហើយចុចពាក្យ Next




ទី1 ចុចពាក្យ No
ទី2 ហើយចុចពាក្យ Next




ទី1 បំពេញលេខទូរស័ព្ទ
ទី2 ជ្រើសរើស I don't have
បើអ្នកគ្មានគេហទំព័រ
ទី3 ហើយចុចពាក្យ Next




ទី1 ចុចពាក្យ No
ទី2 ហើយចុចពាក្យ
Next




ហើយចុចពាក្យ Next



# សូមអរគុណ